# កិច្ចការបញ្ចប់មេរៀនទី១២-គុណម្ដាយឪពុក

➢ **អំណាន:** ចូរច្រៀងចម្រៀងខាងក្រោម រួចឆ្លើយនឹងសំណួរ ។

ចម្រៀង: លំនាំបទខ្ញុំមានមាត់សម្រាប់និយាយ

១. ខ្ញុំមានពុកម៉ែអ្នកមានគុណ ធ្លាប់រែកពុនចិញ្ចឹមគ្រួសារ
ម៉ែដេរប៉ះចម្អិនអាហារ ពុកធ្វើការភ្ជួរចម្ការស្រែ
បន្ទរ៖ មែនហើយភ្ជួរចម្ការស្រែ ។

២. ពុកម៉ែខ្ញុំខិតខំធ្វើការ ទាំងទ្វេហារពុំដែលត្អូញត្អែរ
ការងាររាជការចម្ការស្រែ ធ្វើហូរហែពុំខ្លាចនឿយហត់
បន្ទរ៖ មែនហើយពុំខ្លាចនឿយហត់ ។

៣. ខ្ញុំស្រឡាញ់គោរពលោកណាស់ ព្រោះលោកចាស់ពូកែទ្រាំអត់
គុណធំធេងគ្មានដែនកំណត់ ទោះសមុទ្រក៏ប្រៀបពុំបាន
បន្ទរ៖ មែនហើយក៏ប្រៀបពុំបាន ។

គូសសញ្ញា ✓ ក្នុងប្រអប់ ☐ ចម្លើយមួយដែលត្រឹមត្រូវ ។

១. តើចម្រៀងខាងលើនិយាយពីអ្វី ?

☐ក. គុណម្ដាយឪពុក ☐ខ. ចម្រៀង តន្ត្រី
☐គ. របរកសិកម្ម ☐ឃ. ដំណើរកម្សាន្ត

២. តើឪពុកម្ដាយមានគុណចំពោះកូនដូចម្ដេច ?

☐ក. ផ្ដល់កំណើត ចិញ្ចឹមបីបាច់ ថែរក្សា ផ្ដត់ផ្ដង់ ☐ខ. ផ្ដល់អាហារ
☐គ. ការសិក្សា ☐ឃ. ដំណើរកម្សាន្ត

៣. តើចម្រៀងខាងលើមានប៉ុន្មានវគ្គ ?

☐ក. មានពីរវគ្គ ☐ខ. មានបីវគ្គ
☐គ. មានបួនវគ្គ ☐ឃ. មានប្រាំវគ្គ



LIVEWORKSHEETS

៤. ចូរគូសភ្ជាប់ពីសំណេរពាក្យ ទៅសំណួរពាក្យ ឱ្យបានត្រឹមត្រូវ ?

| សំណេរពាក្យ | សំណួរពាក្យ |
|---|---|
| ចិញ្ចឹម | [ ចំ-កា ] |
| សមុទ្រ | [ រាជៈ-កា ] |
| រាជការ | [ សុ-ភៈ-មង់-គល់ ] |
| ចម្ការ | [ ចិញ-ចឹម ] |
| សុភមង្គល | [ សៈ-ម៉ុត ] |

៥. ចូររកបដិសព្ទនឹងពាក្យ " នឿយហត់ "

☐ក. ពិបាក ☐ខ. ស្រណុក ☐គ. ធុញទ្រាន់ ☐ឃ. សប្បាយ

៦. ចូររកវេវចនសព្ទនឹងពាក្យ " ទទួលទាន "

☐ក. បរិភោគ ☐ខ. ទទួលបាន ☐គ. បានទទួល ☐ឃ. ដំណើរ

៧. ចូររកសទិសសព្ទនឹងពាក្យ " គុណ "

☐ក. កន់ ☐ខ. គន់ ☐គ. គន ☐ឃ. គុន

៨. ចូរគូសសញ្ញាព្រួញភ្ជាប់ឃ្លាខាងក្រោម ឱ្យបានជាវគ្គចម្រៀងត្រឹមត្រូវ ?

| | |
|---|---|
| ពុកម៉ែខ្ញុំខិតខំធ្វើការ | ធ្វើហូរហែពុំខ្លាចនឿយហត់ |
| ខ្ញុំមានពុកម៉ែអ្នកមានគុណ | ពុកធ្វើការភ្ជួរចម្ការស្រែ ។ |
| ការងាររាជការចម្ការស្រែ | ទាំងទ្វេហារពុំដែលត្អូញត្អែរ |
| ម៉ែដេរប៉ះចម្អិនអាហារ | ធ្លាប់រែកពុនចិញ្ចឹមគ្រួសារ |

> ## សំណេរ

៩. ចូរពន្យល់ពាក្យខាងក្រោម ។

- គុណ (ន) .............................................................................................។


LIVEWORKSHEETS

- វិន័យ (ន) ........................................................................................។
- ចិញ្ចឹម (កិ) ......................................................................................។
- ផ្គត់ផ្គង់ (កិ) ....................................................................................។

១០. ចូរជ្រើសរើសពាក្យ ឬកន្សោមពាក្យក្នុងប្រអប់ទៅបំពេញល្បះខាងក្រោមឱ្យបានត្រឹមត្រូវ ។

| នឿយហត់ | រាជការ | ខិតខំ | ចម្អិន | ចិញ្ចឹម | គុណ | ភ្ជួរ | ត្អូញត្អែរ |
|---|---|---|---|---|---|---|---|

ខ្ញុំមានពុកម៉ែអ្នកមាន............ ធ្លាប់រែកពុន............គ្រួសារ

ម៉ែដេរប៉ះ..............អាហារ ពុកធ្វើការ............ចម្ការស្រែ

បន្ទរ៖ មែនហើយភ្ជួរចម្ការស្រែ ។

ពុកម៉ែខ្ញុំ...............ធ្វើការ ទាំងទ្វេហារពុំដែល..............

ការងារ............ចម្ការស្រែ ធ្វើហូរហែពុំខ្លាច...............

បន្ទរ៖ មែនហើយពុំខ្លាចនឿយហត់ ។

១១. ចូររៀបពាក្យ ឬកន្សោមពាក្យក្នុងប្រអប់ទៅបំពេញល្បះខាងក្រោមឱ្យបានត្រឹមត្រូវ ។

ក.

| ខ្ញុំ | ណាស់។ | អ្នកមានគុណ | ស្រឡាញ់ | គោរព |
|---|---|---|---|---|

- ................................................................................................

ខ.

| គុណ | ដែន | គ្មាន | កំណត់ ។ | ធំធេង |
|---|---|---|---|---|

- ................................................................................................


LIVEWORKSHEETS